# ទីតាំងប្រល័យពូជសាសន៍នៅស្រុកព្រៃកប្បាស ទ្រាំង សំរោង និង បូរីជលសារ ខេត្តតាកែវ

ដោយ ផេង ពង្សរ៉ាស៊ី

## ១) ស្រុកព្រៃកប្បាស

ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០១

ទីតាំងសម្លាប់វត្តចារ លេខកូដភូមិសាស្ត្រៈ ២៦០៦០៩

វត្តចារ ជាវត្តមួយស្ថិតនៅក្នុងភូមិចារ ឃុំចារ ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ វត្តនេះស្ថិតនៅក្នុងចំនុចខ្សែស្របb **N 11$^{0}$ 12' 00 : 52** និងរយៈទទឹង **E 104$^{0}$ 55' 03 : 21** នៃការកំណត់តាមរយៈម៉ាស៊ីនកត់ត្រាតាមផ្កាយរណប ដែលបានប្រើនៅម៉ោង១០:០០នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០១ ។ វត្តចារ បច្ចុប្បន្នត្រូវបានកែឆ្នៃយ៉ាងថ្មីសន្ធាងក្រោមការរៀបចំយ៉ាងត្រឹមត្រូវរបស់គណៈកម្មការវត្ត ។ ប៉ុន្តែបើរំលឹកដល់រឿងរ៉ាវពីសម័យខ្មែរក្រហមវិញ វត្តចារ ជាវត្តមួយដែលពួកខ្មែរក្រហមយកធ្វើជាមន្ទីរពេទ្យឃុំរបស់វា ។ មិនតែប៉ុណ្ណោះក្នុងបរិវេណវត្តទាំងមូល ពោរពេញដោយរណ្តៅខ្មោចស្ទើរសុះដី ។ លោកតាមាស ឈៀងបាន និយាយពីហេតុការណ៍នេះថា គាត់កាលនោះជាពេទ្យបូរាណនៅប្រចាំពេទ្យវត្តចារនេះ ។ មន្ទីរពេទ្យស្ថិតនៅខាងលិចព្រះវិហារ ។ ក្នុងមន្ទីរពេទ្យនេះមានបែកចេញជាផ្នែកៗដូចជាកន្លែងស្លសេរ៉ូម ស្លថ្នាំ ធ្វើថ្នាំគ្រាប់ ។ មានកន្លែងសម្រាប់ព្យាបាលមួយស្ថិតនៅខាងជើងព្រះវិហារ ។ លោកតាគឺជាពេទ្យបុរាណម្នាក់ដែលមាននាទីជាអ្នកធ្វើថ្នាំឆ្នាំង និង ថ្នាំដុសថ្នាំរិត ។ លោកតាក៏ជាអ្នកដើររកថ្នាំលើព្រៃភ្នំសម្រាប់ព្យាបាលជម្ងឺប្រចាំមន្ទីរពេទ្យវត្តចារដែរ ។ អ្នកជម្ងឺជាច្រើនត្រូវបានព្យាបាលដោយលោកតាដូចជាជម្ងឺគ្រុនក្តៅ ថ្លោះគ្រិច គ្រុនចាញ់ ។ល ។ ក្រោមសំណួរថា តើលោកតាអាចរៀបរាប់មុខថ្នាំខ្លះបានទេ ពេលគ្រុនម្តងៗ? ចម្លើយឆ្លើយថា «បាន! ប៉ុន្តែមិនចាំអស់ទេ» ។ គាត់បានប្រាប់ថា «ខបម៉ាថាជម្ងឺគ្រុនក្តៅ គឺគេត្រូវយកធាតុផ្សំរវាងៈ ស្នូលពោត ឫសត្នោត ឫសដូង ឫសស្លា គល់កញ្ឆា យកមកដាំទឹកហូប ។ ចំណែកជម្ងឺគ្រុនចាញ់វិញគឺមានធាតុផ្សំដូចជាៈ ដើមទន្រ្ទានខែត្រ ខ្នុរសម្ង បណ្តូលពេជ្រ សម្បកខ្នុរ ស្តៅ និងប៉ុន្មានមុខទៀត(មិនចាំ)» ។ លោកតាមានប្រសាសន៍បន្តថាជម្ងឺដែលខស្សហ៍ជួបប្រទះជាងគេគឺជម្ងឺហើមខ្លះដីវជាតិ ។ ជម្ងឺនេះមិនងាយនឹងព្យាបាលទេ ព្រោះជីវភាពនាពេលនោះមិនគ្រប់គ្រាន់ ។ មានអ្នកជម្ងឺភាគច្រើនដែលមិនអាចព្យាបាលបាននៅក្នុងមន្ទីរពេទ្យវត្តចារនេះ ព្រោះគ្មានថ្នាំគ្រប់គ្រាន់ និងខ្វះការយកចិត្តទុកដាក់ ។ អ្នកជម្ងឺខ្លះត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យស្រុក ឯអ្នកជម្ងឺខ្លះទៀតត្រូវស្លាប់នៅហ្នឹងកន្លែង ។ លោកតាបានប្រាប់ថា អ្នកជម្ងឺស្លាប់ជារៀងរាល់ថ្ងៃ ហើយអ្នកសែងខ្មោចយកទៅកប់ក៏មានការងាររធ្វើរាល់ថ្ងៃដែរ ។ កន្លែងកប់សាកសពគឺស្ថិតនៅប៉ែកខាងកើតព្រះ

វិហារ មានរណ្ដៅច្រើនបន្ទូរ ប៉ុន្តែជារណ្ដៅតូចៗអាចដាក់សាកសពបានម្នាក់ ឬពីរនាក់ប៉ុណ្ណោះ ។ លោកតាបញ្ជាក់ថានៅពីលើរណ្ដៅនិមួយៗ មានដាំចេកពីលើយ៉ាងស៊ុបទ្រុប ហើយល្អទៀតផង ។ តាមការប៉ាន់ស្មានរបស់លោកតាថា នៅជុំវិញបរិវេណវត្តចារគឺមានរណ្ដៅរាប់រយ និងមានសាកសពក៏រាប់រយដែរ ។ ប៉ុន្តែបច្ចុប្បន្នដើមចេក និងរណ្ដៅទាំងនោះ ត្រូវបានឈូសឆាយឲ្យក្លាយទៅជាដីរាបស្មើ មើលទៅហាក់ដូចជាគ្មានរឿងអ្វីកើតឡើងទាល់តែសោះ ប៉ុន្តែអ្វីដែលជាការពិត វានៅតែជាការពិតដដែលមិនអាចលប់បំបាត់បានឡើយ ។

## ទីតាំងសម្លាប់ទួលវែង ឬ ទួលត្រពាំងវែង លេខកូតភូមិសាស្ត្រ: ២១០៦១០

ទួលវែង ជាទួលមួយដែលវែងហើយត្រូវបានប្រជាជននិយមហៅតាំងពីដើមមក ។ ចំណែកឯទួលត្រពាំងវែង ក៏ជាឈ្មោះតែមួយនឹងទួលវែងដែរ ប៉ុន្តែចំឡែកត្រង់ថាទួលវែងនេះមានត្រពាំងមួយយ៉ាងវែងនៅក្បែរទួលនេះទៀត ទើបប្រជាជនជាច្រើននាំគ្នាហៅថា ទួលត្រពាំងវែង ។ នៅក្នុងរបបខ្មែរក្រហម ទួលនេះក៏ជាទួលសម្រាប់កប់សាកសពមួយក្នុងមូលដ្ឋានឃុំចារដែរ ។ រឿងរ៉ាវជាច្រើននៅលើទួលនេះ ត្រូវបាននិយាយប្រាប់ដោយប្រជាជននៅភូមិចារ ឃុំចារ ជាពិសេសមនុស្សដែលមានវ័យចំណាស់ៗ ហើយសុទ្ធតែធ្លាប់បានឆ្លងកាត់ជាក់ស្ដែងក្នុងអំឡុងពេលកាន់អំណាចរបស់ខ្មែរក្រហម១៩៧៥-៧៩នៅមូលដ្ឋានឃុំចារផ្ទាល់ ។ លោកតា ម៉ន ម៉េត អាយុ៦៥ឆ្នាំ បាននិយាយពីសកម្មភាពរបស់គាត់ទាក់ទងនឹងការឃើញផ្ទាល់ភ្នែកនូវការយកមនុស្សទៅសម្លាប់នៅទួលត្រពាំងវែងប្រាប់ថា «កាលពីជំនាន់ប៉ុលពត ខ្ញុំមានតួនាទីជាសង្គមកិច្ចដែលមានតាហេង ជាប្រធាន ។ ការងាររបស់ខ្ញុំពេលនោះចល័តរហូត ជួនកាលមានបញ្ជាឲ្យទៅកាប់ឈើ រែកដី ឬដឹកជញ្ជូនបាយ និងទឹកថ្នាំទៅឲ្យអ្នកធ្វើការនៅតាមភូមិផ្សេងៗ ។ ថ្ងៃមួយ (មិនចាំ) នៅពេលដែលខ្ញុំដឹកជញ្ជូនបាយស្ងួត និងថ្នាំយកទៅឲ្យកងឈ្លបនៅលើទួលមួយក្នុងភូមិក្ដាច់ ឃុំចារ ក៏បានឃើញហេតុការណ៍មួយកើតឡើងគឺបានឃើញពួកឈ្លបឃុំកំពុងជីករណ្ដៅ ។ ក្នុងចំណោមឈ្លបទាំងនោះ ខ្ញុំបានស្គាល់ម្នាក់ឈ្មោះ ចៀន ប៉ុន្តែបច្ចុប្បន្នស្លាប់ហើយ ។ ខ្ញុំបានលួចសួរទៅចៀន ហើយចៀនបានឆ្លើយថារណ្ដៅដែលជីកហ្នឹងគឺសម្រាប់ដាក់អាចម៍គោ ។ ដល់

ថ្ងៃបន្ទាប់ពេលព្រលឹមឡើងខ្ញុំបានទៅកន្លែងនោះជាមួយតា ឈៀង(ពេទ្យបុរាណ)ម្ដងទៀត ។ ទៅដល់ទីនោះភ្លាមស្រាប់តែភ្ញាក់ព្រើត ព្រោះឃើញរណ្ដៅដែលជីកម្សិលមិញដោយកងឈ្លប ពេញទៅដោយសាកសពដែល មានលុបដីបន្តិចៗពីលើប៉ុណ្ណោះ ។ ចំណែករណ្ដៅមួយទៀតដែលស្ថិតនៅខាងកើតមិនទាន់មានឃើញអ្វីនៅឡើយទេ» ។ និយាយបណ្ដើរធ្វើកាយវិការបណ្ដើរ មើលទៅរឿងនេះចាំច្បាស់ខ្លាំងណាស់នៅក្នុងចិត្តរបស់គាត់ ថ្វីត្បិតតែវាកន្លងផុតទៅជាង២០ឆ្នាំក៏ដោយ ។ ចំណែកលោកអ៊ំសាន្ត សុខវិញថាថ្ងៃដែលពួកកងឈ្លបជីករណ្ដៅនោះ គាត់បានដឹងថាមានការឃាត់មនុស្សទុកប្រហែលពី៣០-៤០គ្រួសារ ។ បន្ទាប់មកមានការកោះ

ប្រជុំមួយ ដោយចាត់ឲ្យពួកមូលដ្ឋានចាស់ទាំងអស់មកស្នួងនៅខាងជើងវត្តចារ ដោយទុកតែពួកថ្មីចំនួន៣០-៤០ គ្រួសារប៉ុណ្ណោះនៅស្នួងបង្ហើយនៅលើទួលវែង ។ លោកអ៊ឹំប្រាប់ថាអ្នកបើកអង្គប្រជុំឈ្មោះ អាហ៊ិន សព្វថ្ងៃ ទៅនៅធ្វើគ្រូខសថបុរាណនៅភ្នំពេញ ។ ប៉ុន្តែក៏មានផ្ទះមួយទៀតនៅជិតវត្តឈ្មោះក្នុងទឹកដីឃុំចារនេះដែរ ។ លោក អ៊ឹំសាន្ត សុខបានរៀបរាប់បន្តថា ពួកខ្មែរក្រហមមានវិធីរបស់វាក្នុងការសម្លាប់ ដូចថាមុខសញ្ញាដែលត្រូវជ្រើសរើសយកទៅវៃយប់ហ្នឹង គឺល្ងាចហ្នឹងគេប្រមូលប្រជុំ ។ អត្ថន័យនៃការប្រជុំគឺសុំឲ្យផ្លាស់ទីលំនៅ អាខ្លះ គេថាផ្លាស់ពីភូមិនេះទៅភូមិនោះ ។ ក្រោយការប្រជុំក៏ចាប់ផ្ដើមអនុវត្តភ្លាមៗនូវកម្មវិធីដែលបាន ប្រជុំ ។ លោកអ៊ឹំបានបន្តថាប្រជាជនដែលយកទៅសម្លាប់នៅត្រពាំងវែងហ្នឹងច្រើនតែប្រជាជនមកពីក្រៅ ។

ទីតាំងទួលត្រពាំងវែង ស្ថិតនៅក្នុងភូមិចារ ឃុំចារ ស្រុកព្រៃកប្បាស និងស្ថិតនៅចន្លោះខ្សែស្រប **N $11^0$ 10' 37 : 69** និងរយៈទទឹង **E $104^0$ 54' 20 : 50** នៃការកំណត់តាមរយៈម៉ាស៊ីនកត់ត្រា តាមផ្កាយរណបដែលបានប្រើនៅម៉ោង១០ៈ៣០នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០១ ។

## ទីតាំងទួលកប់សេះ លេខកូដភូមិសាស្ត្រៈ ២១០៦១១

ទីតាំងទួលកប់សេះ ជាទីតាំងសម្លាប់មនុស្សកាលពីជំនាន់ប៉ុលពត ។ ប្រជាជនដែលយកមកសម្លាប់នៅទីនេះ ភាគច្រើនយកមកពីស្រុក៥២(ស្រុកសំរោងទង) ខេត្តកំពង់ស្ពឺ ។ សាក្សីម្នាក់ឈ្មោះ សាធ សាអែម អាយុ៥២ឆ្នាំ បច្ចុប្បន្នជាមេឃុំចារ បានរៀបរាប់ថា អ្នកទោសដែលយកមកសម្លាប់នៅទួលកប់សេះនេះសុទ្ធតែអ្នកនៅក្បែរផ្ទះគាត់ទាំងអស់កាលពីសម័យប៉ុលពត ។ អ្នកទាំងនោះសុទ្ធតែត្រូវទទួលឲ្យផ្លាស់ប្ដូរទីលំនៅទៅភូមិថ្មី ។ ប៉ុន្តែគាត់មិនតម្រូវឲ្យផ្លាស់ទេ ព្រោះគាត់ជាប្រជាជនបញ្ញើរ ។ ឯអ្នកដែលត្រូវផ្លាស់ប្ដូរនោះជាប្រជាជនថ្មី ។ ចំណែករឿងហេតុក្រោយៗពីការផ្លាស់ប្ដូរទីលំនៅយ៉ាងណានោះ លោកមេឃុំមិនបានដឹងដោយផ្ទាល់ទេ ប៉ុន្តែគាត់បានស្ដាប់សេចក្ដីបរិយាយពីការសម្លាប់ប្រជាជនថ្មីនៅលើទួលកប់សេះនេះផ្ទាល់ពីអតីតមេពេជឃាតម្នាក់(បច្ចុប្បន្នស្លាប់)កាលពីដើមទស្សវត្ត៨០ថា ប្រជាជនថ្មីដែលបានប្រមូលមក គឺបានធ្វើពិធីជប់លៀងមួយមុននឹងប្ដូរលំនៅទៅកន្លែងផ្សេង ។ ចំណែកពេលវេលាចេញដំណើរ គឺពួកគេ(កងឈ្លប)លៃយ៉ាងណាឲ្យចំពេលព្រលប់ៗ ។ ពេលចេញដំណើរទៅ ពួកកងឈ្លបបានរៀបចំគំរោងការយ៉ាងលម្អិតមួយដើម្បីបង្វែងដានគឺ មានគ្នាវាមួយក្រុមសម្រាប់ស្ទាក់សួរអ្នកនាំអ្នកទោសដែលត្រូវផ្លាស់ប្ដូរទីលំនៅ ហើយធ្វើជាចងទាហានខ្មែរក្រហមនោះបណ្ដើរយកទៅបាត់ ឯប្រជាជនក៏ត្រូវចងដែរ ។ ប៉ុន្តែតាមការអះអាងពីលោកអ៊ឹំថា ទាហានខ្មែរក្រហមដែលបានចងនោះ គឺត្រូវស្រាយវិញនៅពេលដែលបាត់ពីមុខប្រជាជន ។ចំណែកឯប្រជាជន

មិនត្រូវបានស្រាយវិញទេ ។ លោកអ៊ឹំបានរាយការណ៍បន្តថាពេលដែលចងអ្នកទោសហើយ ក៏បណ្តើរយកទៅដោយដាច់ៗគ្នា ។ មានអ្នកពិឃាតម្នាក់នៅពួនអែបដើមត្នោតមួយជិតរណ្តៅ ពេលបណ្តើរអ្នកទោសមកដល់គល់ត្នោតនោះ អ្នកចាំវ៉ៃក៏ដាក់មាំុងរួចរុញអ្នកទោសចូលរណ្តៅទៅ ។ ចំណែកកូនក្មេង ពួកវាបានចាប់គ្រវែងទាំងរស់ចូលក្នុងរណ្តៅ ហើយវ៉ៃអ្នកផ្សេងៗទៀតគ្របពីលើ ។ នៅទួលកប់សេះនេះ មានមួយរណ្តៅ និងមានអ្នកស្លាប់ប្រហែលពី៤០ទៅ៥០នាក់ ។ ទីតាំងនេះត្រូវបានកំណត់ទុកដោយម៉ាស៊ីនកត់ត្រាភូមិសាស្ត្រតាមផ្កាយរណបនូវចំនុចខ្សែស្រប **N 11⁰ 11' 22 : 50** និងយេៈទទឹង **E 104⁰ 54' 22 : 91** ។

## ទីតាំងសម្លាប់ភូមិស្នន់មុនី ឬ ចម្ការតាសែម លេខកូដភូមិសាស្ត្រៈ ២១០៦១២

ចម្ការតាសែម ស្ថិតក្នុងភូមិស្នន់មុនី ឃុំព្រៃផ្តៅ ស្រុកព្រៃកប្បាស ។ ប្រជាជនក្នុងភូមិភាគច្រើនសុទ្ធតែបានដឹងពីការសម្លាប់មនុស្សនៅចម្ការតាសែមកាលពីសម័យប៉ុលពត ។ លោកអ៊ឹំ ឈិន លី បច្ចុប្បន្នអាយុ៥៣ឆ្នាំ ជាមេភូមិស្នន់មុនី គាត់ជាកូនប្រសាររបស់តាសែមម្ចាស់ចម្ការនេះបានរៀបរាប់ឲ្យដឹងថា ពិតមែនតែគាត់មិនបានរស់នៅក្នុងទឹកដីភូមិស្នន់មុនីមែន ប៉ុន្តែរឿងរ៉ាវដែលបានកើតឡើងនៅភូមិស្នន់មុនី ពិសេសនៅលើចម្ការតាសែមគាត់បានដឹងទាំងអស់ ។ ចម្ការតាសែម ជាចម្ការរបស់ឪពុកក្មេកគាត់កាលពីជំនាន់មុនរបបខ្មែរក្រហម ។ លោកអ៊ឹំត្រូវជម្លៀសចេញទៅនៅខេត្តកំពង់ស្ពឺតាំងពីឆ្នាំ១៩៧៥មក ។ ក្រោយឆ្នាំ១៩៧៩ លោកអ៊ឹំបានវិលមករស់នៅស្រុកកំណើតវិញជាមួយប្រពន្ធរបស់គាត់វិញ ។ លោកអ៊ឹំបានរៀបរាប់ពីសកម្មភាពនានានៅចម្ការតាសែមប្រាប់យើងតាមដែលគាត់ស្រាវជ្រាវថា នៅឆ្នាំ១៩៨០មានមេឃុំឈ្មោះប្រាក់ អុន បាននាំប្រជាជនមួយចំនួនមកគាស់រណ្តៅនៅចម្ការតាសែម ។ ក្នុងនាមជាម្ចាស់ចម្ការដែលបន្តកេរ្តិ៍តំណែលពីឪពុកគាត់និងប្រពន្ធបានទៅឈរមើលការគាស់រណ្តៅនោះ ។ គាត់បានប្រទះឃើញនៅក្នុងរណ្តៅពេញទៅដោយសាច់និងឆ្អឹងដែលរឡេះរលួយដូចផ្អក ស្ទើរតែមិនហ៊ានមើលផង ។ ចំណែកឯរណ្តៅខ្លះទៀតពេលគាស់ទៅគឺអត់ឃើញមានខោអាវទាំងអស់ ។ លោកអ៊ឹំបានសរុបរណ្តៅទាំងអស់មានចំនួន២៨រណ្តៅដែលមានរណ្តៅធំ២០ និងរណ្តៅតូចចំនួន៨រណ្តៅ ។ ឯចំនួនសាកសពក្នុងមួយរណ្តៅធំមានចំនួនប្រហែលមិនតិចជាង៣០ទៅ៥០ទេ ។ ចំណែក៨រណ្តៅតូចវិញ ក្នុងមួយរណ្តៅមានពីពីរទៅបីនាក់ទៀត ។ អញ្ចឹងបើគុណនឹងចំនួនជាមធ្យមទៅឃើញថា ចំនួនសាកសពសរុបគឺប្រហែលពី១០០០ ទៅ ១២០០នាក់ ។ អ្នកទោសដែលយកមកសម្លាប់នៅទីនេះ ភាគច្រើនតែកងចល័ត ។ លោកអ៊ឹំរៀបរាប់ថា ឲ្យតែបាត់កងចល័តពីណាមក គឺប្រាកដជាយកមកសម្លាប់នៅទីនេះហើយពេលសម្លាប់ម្តងៗតែងតែមានចាក់មេក្រូបន្ទប់រាល់តែពេល ។ ចំពោះកងចល័តដែលបានមកស្លាប់នៅទីនោះ ភាគច្រើនយកមកពីទន្លេបាទី ពីស្រុកព្រៃកប្បាសផ្ទាល់ និងពីស្រុក៥២(ស្រុកសំរោងទង) ។ ហើយមួយ

ចំនួនធំនៃអ្នកទោស គឺជាយុវជន និងយុវនារី មិនមានលាយមនុស្សចាស់ទេ ។ ពួកសន្តិសុខកងស្រុកដែលមកប្រចាំការនៅចម្ការតាសែមនេះមានចំនួនប្រហែលមួយកងអនុសេនាតូច ។
លោកអ៊ំបានបញ្ជាក់បន្ថែមថាបើតាម មតិពីប្រជាជននៅភូមិព្រៃឈើទាលក៏ដូចជាអ្នកមានស្រុកកំណើតកើតជានៅស្រុកស្ទន់មុនីនេះថាមុននឹងសម្លាប់ មនុស្សឃើញតែរទេះដឹកមនុស្សមក មានសាក់កាដូមានឥវ៉ាន់ ។ ដល់ពេលដឹកចូលមកដល់ មិនយូរប៉ុន្មានសម្លេងមេក្រូនឹងឮឡើង ។ លុះដល់ព្រលឹមថ្ងៃស្អែកមនុស្សទាំងអស់ត្រូវបាត់លែងឃើញទាំងអស់ ។ ប្រជាជនដែលនៅធ្វើការជុំវិញទីតាំងនេះ ម្នាក់ៗសុទ្ធតែតក់ស្លុតនឹងសម្លេងមេក្រូនេះ ។ លោកអ៊ំបាននិយាយថាឆ្នាំដែលសម្លាប់ខ្លាំងជាងគេគឺនៅចុងឆ្នាំ១៩៧៦និងដើមឆ្នាំ១៩៧៧ ។ ចំពោះមូលហេតុដែលពួកខ្មែរក្រហមយកទីតាំងទួលចម្ការតាសែមនេះជាទីតាំងសម្លាប់មនុស្ស តាមកាសន្និដ្ឋានរបស់លោកអ៊ំ ឈិន លីថាប្រហែលជាភូមិសាស្ត្រនៅទីនេះស្ងាត់ហើយគ្មានផ្លូវចេញចូល ។ ម្យ៉ាងទៀតប្រជាជនដែលធ្លាប់រស់នៅភូមិនេះ ក៏ត្រូវជម្លៀសចេញអស់ដែរ ដូច្នេះជាឱកាសល្អមួយសម្រាប់ការសម្លាប់មនុស្សនៅភូមិស្ទន់មុនីនេះ ។ ទីតាំងសម្លាប់ចម្ការតាសែមត្រូវបានកំណត់ទុកដោយម៉ាស៊ីនកត់ត្រាភូមិសាស្ត្រតាមផ្កាយរណប នូវចំនុចខ្សែស្រប **N 11$^{0}$ 09' 32 :25** និងយេៈទទឹង **E 104$^{0}$ 51' 10 : 39** ។

## ២) ស្រុកបូរីជលសារ

ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០១

ទីតាំងសម្លាប់ និង គុកនៅទួលអង្គក្រូច លេខកូតភូមិសាស្ត្រៈ២១០៣០១

ទួលអង្គក្រូច ជាទួលមួយដ៏ធំល្វឹងល្វើយស្ថិតនៅភូមិអង្គក្រូច ឃុំបូរីជលសារ ស្រុកបូរីជលសារ ខេត្តតាកែវ តំបន់១៣ ភូមិភាគនិរតី ។ ហើយក៏ស្ថិតនៅក្នុងចំណុចខ្សែស្រប **N 10$^{0}$ 51' 18 : 94** និងយេៈទទឹង **E 104$^{0}$ 56' 49 : 15** នៃការកំណត់តាមរយៈម៉ាស៊ីនកត់ត្រាតាមផ្កាយរណប ដែលបានប្រើនៅម៉ោង១១ៈ៣៥នាទី នាថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ២០០១ ។ បច្ចុប្បន្ននេះនៅលើទួលអង្គក្រូចមានសាលាបឋមសិក្សាមួយសង់អំពីឥដ្ឋ និងមានវត្តអង្គក្រូចមួយនៅក្បែរផង ។ កាលពីសម័យប៉ុលពត ពិសេសនៅឆ្នាំ១៩៧៧ និង១៩៧៨ ទួលនេះត្រូវបាន កំណត់យកធ្វើជាកន្លែងសម្លាប់មនុស្សដ៏ធំមួយនៅឃុំបូរីជលសារ ។ ការសម្លាប់មនុស្សភាគច្រើនគឺជាទាហាន និងគ្រួសារទាហានលន់ណុលដែលពួកខ្មែរក្រហមចាប់បាន ។ លោកពូ ណៅ សេង អាយុ ៥៦ឆ្នាំ សម័យប៉ុល ពតនៅភូមិអង្គក្រូច ឃុំបូរីជលសារ ស្រុកបូរីជលសារ ដែលកាលនោះ(១៩៧៥-៧៩) លោកពូមានតួនាទី ជាអ្នកដើររកបន្លែឲ្យរោងបាយ ក៏បានដឹងថាមានគុកសន្តិសុខសម្រាប់ឃុំឃាំងទាហាន

មួយកន្លែងនៅក្នុងបរិវេណវត្តអង្គក្រូច ។ គាត់ដឹងទៀតថាមន្ទីរនោះមានប្រធានឈ្មោះ អាឆាន ។ ចំណែកអាចត់ជាវរៈសេនាតូចក្នុងគុកហ្នឹង ។ ទាហានដែលត្រូវយកសម្លាប់នៅទីនេះគឺជាទាហានលន់ណុលទាំងគ្រួសារៗដែលមានលាយចំរុះគ្នា ប៉ុន្តែភាគច្រើនក្នុងខេត្តតាកែវ ។ ការសម្លាប់ប្រព្រឹត្តិទៅនៅឆ្នាំ១៩៧៧ ហើយពេលយប់គឺជាពេលសំខាន់ក្នុងការកម្ទេចមនុស្សទាំងនោះចោល ។ ឯរណ្តៅសាកសពក៏មានចំនួនច្រើនដែរ គឺស្ថិតនៅពេញទីទួលអង្គក្រូចដែលមានបរិវេណប្រមាណកន្លះគីឡូបួនជ្រុង ។ អ្នកស្រុកម្នាក់បាននិយាយថារណ្តៅមានតូចមានធំ ខ្លះជីកទៅឃើញក្បាលបី ខ្លះប្រាំ ខ្លះប្រាំពីរ ។ល ។ ស៊ឹម ចន្ថា អាយុ៣៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិអង្គក្រូចបាននិយាយថា នៅឆ្នាំ១៩៧៨ គាត់បានរត់ពីស្រុកកោះអណ្តែត កាត់តាមទួលអង្គក្រូចនេះឆ្ពោះមកកាន់ផ្ទះលោកតារបស់គាត់ដែលមានចម្ងាយមិនឆ្ងាយប៉ុន្មានពីទីតាំងសម្លាប់ ។ ពេលនោះគាត់បានឃើញពួកខ្មែរក្រហមចងប្រជាជនប្រហែលជា២០ទៅ៣០នាក់សុទ្ធតែប្រជាជនធម្មតា យកទៅសម្លាប់នៅលើទួលអង្គក្រូច ។ ឃើញដូច្នោះ ចន្ថាបានរត់ទៅពួនដើម្បីលួចមើលសកម្មភាពបន្តទៀត ។ គាត់បានធ្វើការប៉ាន់ស្មានថាប្រហែលជា ប្រជាជនទាំងនោះធ្លាប់បានភាសខ្លួនទៅប្រទេសវៀតណាម ហើយត្រូវចាប់បានមកវិញ ។ ចន្ថាមិនបានឃើញ ការសម្លាប់ផ្ទាល់ភ្នែកទេ ប៉ុន្តែគាត់ជឿជាក់ថាពិតជាត្រូវយកមកសម្លាប់នៅទីនោះមិនខាន ។ ចំណែកនៅក្នុងបរិវេណព្រះវិហារវត្តអង្គក្រូច ក៏មានការសម្លាប់ខ្លះដែរ ។ ស៊ឹម ចន្ថា បាន និយាយថាស្ទើរតែគ្រប់ដើមដូងនៅក្នុងបរិវេណវត្ត សុទ្ធតែមានការសម្លាប់មនុស្សដាក់ពីក្រោមរួចទើបដាំដើមដូងពីលើ ។

ចំណែកឯរោងតូចមួយប្រហែលជាបណ្តោយ៣ម៉ែត្រនិងទទឹង១ម៉ែត្រកន្លះ ហើយបច្ចុប្បន្នជារោងម៉ាស៊ីនភ្លើងរបស់វត្ត អតីតជាកន្លែងសួរចម្លើយរបស់ខ្មែរក្រហម ។ ចន្ថាបានប្រាប់ថា កាលពីទើបនឹងបែកឆ្នាំ១៩៧៩និងបន្តមកប៉ុន្មានឆ្នាំក្រោយមកទៀត នៅលើជញ្ជាំងមានស្នាមប្រឡាក់សុទ្ធតែឈាម ចំណែកឯនៅលើកម្រាលឥដ្ឋក៏មានឈាមដែរ ព្រមទាំងមានខ្នោះឃ្នៀងជាច្រើនផង ។ មន្ទីរសួរចម្លើយនេះត្រូវបានរុះរើស្ទើរតែទាំងអស់ដោយគណៈកម្មការវត្ត និងប្រជាជនខ្លះនៅជុំវិញទីនោះ ។ អ្វីដែលបានបន្សល់ទុកនោះគឺជាអតីតបន្ទប់សម្រាប់ធ្វើទណ្ឌកម្មមួយដែលបិទជិតស្ទើរតែគ្មានខ្យល់ចេញចូល ហើយល្ងិតទាំងយប់ទាំងថ្ងៃ ។ ប៉ុន្តែបច្ចុប្បន្នត្រូវបានកែឆ្នៃថ្មី ឲ្យក្លាយទៅជាបន្ទប់ម៉ាស៊ីនភ្លើងប្រចាំវត្តអង្គក្រូចទាំងមូលទៅហើយ ។ ចំពោះការប៉ាន់ស្មានចំនួនសាកសពរួម និងរណ្តៅរួមនោះ លោកណៅ សេង បានសន្និដ្ឋានថា មានរណ្តៅច្រើនជាង១០ ហើយចំនួនសាកសពក៏ច្រើនជាង៩០នាក់ដែរ ។

# ៣) ស្រុកទ្រាំង

ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១

**ទីតាំងវាលទំនាបទឹកស ឬ ទួលព្រៃលើ                                    លេខកូតភូមិសាស្ត្រ៖ ២១១០០៤**

មានទីតាំងសម្លាប់មួយស្ថិតនៅក្នុងភូមិត្រពាំងធំ ឃុំរនាម ស្រុកទ្រាំង ខេត្តតាកែវ ។ ការសម្លាប់មនុស្សនៅលើទួលមួយដែលមានរាងហាក់ដូចជាកូនភ្នំមួយក្នុងទឹកដីភូមិត្រពាំងធំ បានបំផ្លាញជីវិតមនុស្សទាំងគ្រួសារៗនៃត្រកូលទាហាន ប៉ូលិស និងមន្ត្រីរាជការនានាអស់ចំនួនពី១០០-១៥០នាក់កាលពីអំឡុងឆ្នាំ១៩៧៥-៧៩ ។ រឿងរ៉ាវដែលបានកើតឡើងទាំងប៉ុន្មាននៅលើទួលព្រៃលើ ត្រូវបានដឹងឮសុះសាយពេញទាំងភូមិ-ឃុំ ។ លោកអ៊ឹ អូ អ៊ី បច្ចុប្បន្នអាយុ៦០ឆ្នាំ មានតួនាទីជាជំទប់លេខមួយឃុំរនាម បានរៀបរាប់ថាក្នុងរបបខ្មែរក្រហម ជាពិសេសឆ្នាំ១៩៧៥លោកអ៊ឹត្រូវជម្លៀសឲ្យទៅនៅខាងលិចផ្លូវជាតិលេខ៣ ។ ក្រោយមកប្រហែលជា២-៣ខែ លោកអ៊ឹបានមករស់នៅក្នុងភូមកំណើតរបស់ខ្លួនវិញគឺភូមិខ្លោងទ្វារ ឃុំរនាម ស្រុកទ្រាំងរហូតដល់បែកឆ្នាំ១៩៧៩ ។ ការសម្លាប់មនុស្សនៅលើទីទួលព្រៃលើ លោកអ៊ឹមេឃុំប្រាប់ថាគ្មានប្រជាជនណាម្នាក់បានឃើញហេតុការណ៍ផ្ទាល់ភ្នែក ក្រៅពីអតីតពួកកងឈ្លបខ្មែរក្រហមនៅទីនោះឡើយ ដែលគាត់បានអះអាងថាជាមនុស្សមកពីស្រុកឆ្ងាយៗនិយាយរដឺនៗ ។ នៅលើទួលព្រៃលើនេះ លោកអ៊ឹបានត្រឹមតែឃើញសាកសពដែលស្ថិតនៅពាសវាលពាសកាលគ្មានសណ្តាប់ធ្នាប់ប៉ុណ្ណោះ ។ ហើយបើតាមការប៉ាន់ស្មានចំនួនសាកសព លោកអ៊ឹបានប៉ាន់ស្មានថាប្រហែលពី១០០ទៅ១៥០នាក់ ។ ការសម្លាប់គឺគ្មានបានដឹករណ្តៅទេ ។ លោកអ៊ឹបន្តថាបើតាមគាត់បានសួរប្រជាជនខ្លះៗទៅ ទើបដឹងថានៅពេលដែលបែកឆ្នាំ១៩៧៥ភ្លាម ប្រជាពលរដ្ឋដែលចេញមកពីទីក្រុងនានាទូទាំងប្រទេសហើយសំដៅមកស្រុកកំណើតរបស់ខ្លួនវិញនោះ ត្រូវបានឃាត់ទុកដើម្បីសួរនាំពត៌មានពីមុខងារក្នុងជំនាន់លន់ណុល ។ គោលបំណងសំខាន់ក្នុងការស៊ើបសួរគឺសំដៅចង់បានអ្នកជាប់និន្នាការដូចជាប៉ូលិស ទាហាននិងមន្ត្រីរាជការយកទៅសម្លាប់ចោលនៅទួលព្រៃលើនេះ ។ ក្នុងចំណោមប្រជាជនទាំងអស់មានភាគច្រើនត្រូវបានឆ្លើយតាមត្រង់ ។ ប៉ុន្តែក៏មានប្រជាជនខ្លះមិនទុក ចិត្តចំពោះទង្វើរនេះក៏បានឆ្លើយកុហក លាក់លៀមមុខតំណែងរបស់ខ្លួន ហើយប្រកាសខ្លួនថាជាអ្នករត់រ៉ឺម៉ក ឬស៊ីក្លូទៅវិញ ។ មិនយូរប៉ុន្មានការបែងចែកបានកើតមានឡើង អ្នកគ្មានការងារធ្វើ និងអ្នកដែលលាកលៀមតួនាទីត្រូវបានជម្លៀសបន្តទៀត ហើយអ្នកដែលជាប់ឈ្មោះថាជាទាហាន ប៉ូលិស ឬមន្ត្រីរាជការនានា ត្រូវយកទៅសម្លាប់ចោលទាំងអស់នៅទួលព្រៃលើ ។ ក្នុងការសម្លាប់នេះដែរ ពួកសន្តិសុខខ្មែរក្រហមមិនបានប្រើអាវុធសម្លាប់ទេ គឺប្រើដំបង គល់ឫស្សី ដែកគោ្ល់រទេះ.....។ ការសម្លាប់ត្រូវបានបែងចែកពេលវេលាតាមឋានៈខ្ពស់ទាប ។ អ្នកដែលមានឋានៈខ្ពស់ត្រូវយកទៅសម្លាប់មុនគេជាមួយក្រុមគ្រួសារ ចំណែកអ្នកដែលមានឋានៈតូចតាចត្រូវយកទៅសម្លាប់ក្រោយគេ ។ ចុងបញ្ចប់អ្នកទាំងនេះបានបន្សល់ទុកឆ្អឹងសស្វាចនៅលើដីដូចគ្នា ហើយបច្ចុប្បន្នឆ្អឹងទាំងនោះត្រូវបានបំផ្លាញអស់ដោយសត្វគោ សត្វជ្រូក ។ល ។ ទីតាំងនេះត្រូវបានកំណត់យ៉ាងច្បាស់នូវចំណុចខ្សែ

**N 10$^{0}$ 54' 44 : 84** និងរយៈទទឹង **E 104$^{0}$ 44' 28 : 08** នៃម៉ាស៊ីនកត់ត្រាតាមផ្កាយរណប ដែលបានប្រើនៅម៉ោង៩ៈ៣៥ នាទី នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១ ។

## ទីតាំងសម្លាប់ឡតាកុយ លេខកូតភូមិសាស្ត្រៈ ២១១០០៥

ឡតាកុយ ជាឡមួយដែលមាន**តាកុយ**ជាអ្នកមើលការខុសត្រូវក្នុងការដុតខ្មោចកាលពីជំនាន់ប៉ុលពត ។ ឡតាកុយជាឈ្មោះដែលអ្នកស្រុកនិយមហៅតាំងពីស្ថិតក្នុងសម័យប៉ុលពតម្ល៉េះ ហើយបន្តរហូតមកដល់បច្ចុប្បន្ននេះទៀត ។ ប៉ុន្តែបច្ចុប្បន្នឡនេះត្រូវបានបោះបង់ចោលនៅលើដីទួលមួយកន្លែង និងត្រូវបានបំផ្លាញចោលអស់គ្មានសល់ ។ កូនត្នោតជាច្រើនដើម និងស្មៅគ្រប់ប្រភេទបានដុះយ៉ាងទ្រុប់ទ្រុលគ្រប់ពីលើអតីតឡដុតខ្មោចមួយនេះ ។ ឡតាកុយស្ថិតនៅក្នុងភូមិជីទរ ឃុំអង្គខ្នុរ ស្រុកទ្រាំង ខេត្តតាកែវ ។ តាមម៉ាស៊ីនកត់ត្រាតាមផ្កាយរណបទីតាំងឡតាកុយនេះស្ថិតលើខ្សែស្រប **N 10$^{0}$ 50' 36 : 71** និងយេៈទទឹង **E 104$^{0}$ 50' 58 : 31** ដែលបានប្រើនៅម៉ោង១១ៈ១៥ នាទី នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១ ។ តាមការបកស្រាយរបស់លោកពូ ប្រាក់ ម៉ន អាយុ៥៤ឆ្នាំ បច្ចុប្បន្នមានតួនាទីជាប្រធានភូមិជីទរ ឃុំអង្គខ្នុរ ស្រុកទ្រាំង ខេត្តតាកែវ ថាឡតាកុយបានកសាងនៅឆ្នាំ១៩៧៦ សំរាប់ដុតខ្មោចអ្នកជម្ងឺដែលស្លាប់នៅមន្ទីរពេទ្យស្រុក១០៨ ដែលមានទីតាំងស្ថិតនៅមន្ទីរវត្តកកោះ ឥឡូវគេហៅថាវត្តខ្នារកកោះ ។អ្នកជម្ងឺនៅមន្ទីរពេទ្យស្រុកមានស្លាប់ជារៀងរាល់ថ្ងៃហើយត្រូវបញ្ជូនមកកាន់ឡនេះដើម្បីដុត ។ លោកពូប្រធានភូមិនិយាយថាមុនហ្នឹងដុតខ្មោចដែលមានចំនួនពីរ៣ឡើងនោះ គឺត្រូវសម្រាតខោអាវចេញអស់គ្មានសល់ទេទាំងស្រីទាំងប្រុស ។ លោកអ៊ំបានសន្និដ្ឋានថាមនុស្សដែលស្លាប់នេះភាគច្រើនជាប្រជាជនថ្មី ព្រោះកាលណាមានប្រជាជនថ្មីទៅសម្រាកនៅពេទ្យគឺពួកពេទ្យមិនយកចិត្តទុកដាក់ ចំពោះប្រជាជនទាំងនោះទេ ។ ជួនកាលមានការចាក់ថ្នាំឲ្យស្លាប់ទៀតក៏មានដែរ ។ ម្ល៉ោះហើយមួយថ្ងៃៗមានស្លាប់ច្រើនណាស់ ។ លោកអ៊ំបានសន្និដ្ឋានថា យ៉ាងហោចណាស់ក៏មានមនុស្សស្លាប់ប្រហែល២០០នាក់ដែរក្នុងចន្លោះឆ្នាំ១៩៧៥-៧៦ ។ ប៉ុន្តែតាំងពីឆ្នាំ១៩៧៦មកទល់ចុងឆ្នាំ១៩៧៨លោកអ៊ំក៏ដូចបងប្អូនឯទៀតមិនបានដឹងឡើយ ព្រោះត្រូវបានជម្លៀសទៅកាន់តំបន់ឆ្ងាយៗពីទីនោះ ។

## ទីតាំងសម្លាប់នៅភ្នំថ្នក់ លេខកូតភូមិសាស្ត្រៈ ២១១០០៦

ភ្នំថ្នក់ ជាភ្នំមួយដែលស្ថិតក្នុងភូមិភ្នំថ្នក់ ឃុំព្រៃស្លឹក ស្រុកទ្រាំង ។ បច្ចុប្បន្ននៅជុំវិញភ្នំនេះ ត្រូវបានប្រជាជនប្រកបរបរដាំដំឡូងឈើលើដីដ៏មានជីជាតិនៃជើងភ្នំ ។ ប្រជាជនមួយចំនួនបាននាំគ្នាទៅធ្វើផ្ទះនៅតាមជើងភ្នំ ខ្លះធ្វើជារោងចាំដំណាំ អ្នកខ្លះទៀតមានលក់ប្រដាប់ប្រដាផ្សេងៗដើម្បីបំរើប្រជាជនដែលរស់នៅម្តុំ

*នោះ ។ អ្នកមីងឈាង មុំ អាយុ៤១ ជាប្រជាជនរស់នៅភូមិភ្នំថ្នក់(ជើងភ្នំថ្នក់បែកខាងត្បូង) បានរៀបរាប់ថា នៅពេលដែលគាត់តាមមករកឪពុកគាត់ដែលត្រូវពួកខ្មែរក្រហមចាប់យកមកកាន់ភ្នំថ្នក់ គាត់បានឃើញប្រជាជនថ្មីមួយចំនួនរួមទាំងឪពុកគាត់ផងកំពុងតែធ្វើការនៅភ្នំថ្នក់នេះ ។ អ្នកមីងនិយាយពីការងាររបស់ប្រជាជនទាំងនោះថា ខ្លះរែកត្រគៀត ខ្លះរែកដីដំបូក ខ្លះកាប់ដីដាំដំណាំ....។ លុះចប់ពីការងារ គឺតម្រូវឲ្យប្រជាជនទាំងនោះចូលទៅក្នុងជង្រុកស្រូវយ៉ាងធំមួយ ។ ពេលក្រោយមកប្រហែលជា៤ ខែមុនបែកទីក្រុងភ្នំពេញ ប្រជាជនទាំងនោះត្រូវនាំយកទៅសម្លាប់ចោលទាំងអស់ ។ សពខ្លះស្ថិតនៅរាយប៉ាយ ខ្លះស្ថិតក្នុងអន្លង់ធំៗ ។ បរិវេណនៃការសម្លាប់មនុស្សគឺមានទំហំដីខ្ពង់ប្រហែល១៥០ម៉ែត្រ ។ ចំណែកអ្នកមីង រ៉េត អាយុ៣៧ឆ្នាំ រស់នៅភូមិភ្នំថ្នក់ ឃុំព្រៃផ្តៅ បានឲ្យដឹងថា ក្នុងរយៈពេលជាងកន្លះខែមុននេះ មានកសិករម្នាក់បានកាប់ដីដាំដំឡូង ហើយក៏បានប្រទះឃើញមានខោអាវសពព្រមទាំងមានបំណែកឆ្អឹងតូចៗមួយចំនួនទៀត ។ ពេលឆែកមើលក្នុងខោ អាវកសិករនោះបានរកឃើញមានមាសប្រាំហ៊ុននៅក្នុងហោប៉ៅ ។ ហើយនាពេលថ្មីៗនេះ អ្នកមីងបានជីកដីចំហៀងផ្ទះដើម្បីធ្វើអណ្តូងដាក់អាចម៍គោ ស្រាប់តែឃើញមានលលាដ៍ក្បាល៤និងឆ្អឹងខ្លះទៀត ។ គាត់ក៏បានសន្និដ្ឋានថា ប្រហែលជាផ្ទះរបស់គាត់បានសង់នៅលើផ្នូរខ្មោចហើយ ព្រោះបើតាមអ្នកមីងនិយាយថាបានរកគ្រូទស្សទាយទៅ គឺផ្ទះរបស់គាត់បានធ្វើនៅចំពីលើផ្នូរខ្មោច នៅមិនសុខទេ ដាច់ខាតត្រូវរុះរើធ្វើថ្មីក្រៅពីកន្លែងនេះ ។ អ្នកមីងបានសរុបចំនួនសាកសពទាំងអស់ដែលបានស្លាប់នៅភ្នំថ្នក់នេះថាមានចំនួនប្រហែលពី២០០ ទៅ ៣០០នាក់ ។ ទីតាំងភ្នំថ្នក់ត្រូវបានកំណត់ទុកដោយម៉ាស៊ីនកត់ត្រាភូមិសាស្រ្តតាមផ្កាយរណប នូវចំនុចខ្សែស្រប* **N $10^{0}$ 53' 38 : 48** *និងរយៈទទឹង* **E $104^{0}$ 47' 34 : 88** *។*

## ៣) ស្រុកសំរោង

*ថ្ងៃទី២៨-២៩ ខែមិថុនា ឆ្នាំ២០០១*

*ទីតាំងទួលស្វាយដង្កោល* *លេខកូដភូមិសាស្រ្តៈ ២១០៧០៥*

*ទីតាំងទួលស្វាយដង្កោល ស្ថិតនៅក្នុងភូមិស្រីប្រសើ ឃុំស្លា ស្រុកសំរោង។ ទួលនេះស្ថិតនៅឆ្ងាយពីភូមិស្រីប្រសើប្រហែលជាង២គីឡូម៉ែត្រ ។ បច្ចុប្បន្នទួលនេះមានតែមនុស្សមួយគ្រួសារប៉ុណ្ណោះដែលរស់នៅ ។ ក្រៅពីនោះគ្មានមានមនុស្សណាម្នាក់នៅឡើយ ។ លោកពូម៉ុក ចន អាយុ៥៤ឆ្នាំ សព្វថ្ងៃរស់នៅភូមិស្រីប្រសើ ឃុំស្លា ស្រុកសំរោងបានប្រាប់ថា សូម្បីតែដើរឡើងលើទួលនេះក៏មិនដែលមានដែរ ។ ទួលនេះមានទំហំប្រហែលជាពីរហិកតា៤ជ្រុង ហើយខាងលើខ្នងទួលមានស្លាកស្នាមជាស្រះត្រពាំងមួយដែលជាអតីតកន្លែងកប់សាកសពដ៏សម្បើម ក្នុងចំណោមកន្លែងកប់ផ្សេងៗទៀតនៅជុំវិញទួលនេះ ។ ក្រោយឆ្នាំ១៩៧៩រណ្តៅទាំងនេះខ្លះត្រូវបានគាស់ដើម្បីរកមាស ។ ឆ្អឹងលលាដ៍ក្បាលប្រហែលមួយភាគបីត្រូវបានប្រមូលមកដាក់នៅផ្ទះមួយ*

លើទួលនេះ ។  ប៉ុន្តែបច្ចុប្បន្នអដ្ឋិធាតុទាំងនោះមិនបានបន្សល់ទុកឡើយ ។  ចំណែករណ្តៅយ៉ាងច្រើនទៀតដែលមិនបានគាស់ក៏ត្រូវរាបស្មើដោយទឹកភ្លៀងច្រោះដីបញ្ចូល ។  លោកអ៊ឹម៉ុក ចនបានប្រាប់ថា ការសម្លាប់មានច្រើនកន្លែងណាស់ មានទាំងរណ្តៅដែលជីក មានទាំងស្រះ មានទាំងរណ្តៅបេ៥២ដែលទម្លាក់កាលពីជំនាន់លន់ណុល ។ ដោយសារតែជាកន្លែងស្ងាត់ ដាច់ពីភូមិអ្នកស្រុក ទើបការសម្លាប់មនុស្សនៅទីនេះប្រព្រឹត្តិទៅដោយគ្មានប្រជាជនដឹង ។ ការសម្លាប់មនុស្សនៅលើទួលនេះ ធ្វើឡើងដោយមិនរើសពេលវេលាទេ ជួនកាលសម្លាប់ពេលថ្ងៃ ជួនកាលសម្លាប់ពេលយប់ ជាមួយនឹងការចាក់មេក្រូបំភាន់ និងមានអ្នកយាមក្មេងៗរាប់មិនអស់នៅជុំវិញទួលនេះ ។ លោកពូម៉ុក ចន បានរៀបរាប់ថា ក្មេងៗដែលយាមនៅជុំវិញទួលស្វាយដង្កោលនេះមានអាយុមិនលើសពី១២ ឬ១៣ឆ្នាំទេ ហើយកាចណាស់ ឲ្យតែឃើញអ្នកណាដើរកាត់មុខវាពេលដែលកំពុងឈរយាមការសម្លាប់ គឺដាច់ខាតចាប់យកទៅសម្លាប់ភ្លាម ។ អ្នកស្រុកដែលមកស្ទូងដកក្បែរៗបរិវេណសម្លាប់នេះខ្លាចឡើងរួញខ្លួន ហើយមិនហ៊ានដើរទៅណាមកណាឡើយពេលដែលឮសម្លេងមេក្រូបន្លឺឡើង ។ លោកអ៊ឹនិយាយថាមនុស្សដែលបានមកស្លាប់នៅទីនេះ ភាគច្រើនមកពីឃុំដើងកួន ឃុំទ្រា និង ឃុំស្លា ស្រុកសំរោង ។ គាត់បន្តថាចំពោះប្រជាជនអ្នកក្រមិនត្រូវបាននាំយកមកសម្លាប់ទេ ប៉ុន្តែចំពោះអ្នកមានទ្រព្យសម្បត្តិឬឲ្យតែពួកខ្មែរក្រហមគិតថាជាវណ្ណៈមូលធនគឺគេចមិនរួចឡើយ ។ ការសម្លាប់រង្គាលនៅលើទួលស្វាយដង្កោលនេះប្រព្រឹត្តិទៅតែក្នុងរយៈពេលមួយឆ្នាំគត់(មិនចាំឆ្នាំ) ។ ហើយការសម្លាប់នេះទៀតសោត គឺមិនអនុញ្ញាតិឲ្យមានរួចខ្លួនរណាម្នាក់ក្នុងបន្ទុកគ្រួសារឡើយ ។ ល្បិចនៃការយកមនុស្សមកសម្លាប់នៅទួលស្វាយដង្កោលនេះ លោកអ៊ឹរៀបរាប់ថា ប្រជាជនដែលបានដាប់ចោទថាជាអ្នកមានទាំងនោះ ត្រូវមានបញ្ជារឲ្យផ្លាស់ប្តូរទីលំនៅ ហើយជាពិសេសតម្រូវឲ្យទៅដាំដំឡូងនៅលើទួលស្វាយដង្កោលនេះ ។ ពេលជិតមកដល់ទួលនេះ មានបញ្ជាមួយឃាត់មិនឲ្យទៅមុខ ដើម្បីរង់ចាំការអនុញ្ញាតិ ។ មិនយូរប៉ុន្មានគេសង្កេតឃើញមាននាំមួយគ្រួសារទៅបាត់ មួយសន្ទុះមកទៀតឃើញនាំមួយគ្រួសារទៅទៀត ។ ធ្វើយ៉ាងនេះរហូតដល់អស់ ។លោកអ៊ឹនិយាយថាពេលយកគ្រួសារមួយៗមកហ្នឹងគឺយកមកសម្លាប់ហើយ ។ ហើយរយៈពេលនៃការសម្លាប់ម្តងៗគាត់ថាមានរយៈពេលប្រហែលជិតកន្លះថ្ងៃឯណោះ ។ ពួកពិជឃាត ត្រូវបានលោកអ៊ឹបរិយាយថា “ច្រើនពួកនៅខាងលិច គឺនៅភ្នំដីររមៀល ស្រុកត្រាំកក់ឯណោះ ។ ហើយមានអាខ្លះនិយាយរដឹនៗស្តាប់មិនចង់បាន” ។ ចំពោះការសន្និដ្ឋានចំនួនសាកសព និងចំនួនរណ្តៅ ប្រជាជនមួយចំនួនដែលយើងបានជួបនៅក្នុងភូមិស្រីប្រសើ សុទ្ធតែបាននិយាយថាមានចំនួនរាប់ពាន់ និងរណ្តៅជាង២០ ។ ទីតាំងទួលស្វាយដង្កោលត្រូវបានកំណត់ទុកដោយម៉ាស៊ីនកត់ត្រាភូមិសាស្ត្រតាមផ្កាយរណប នូវចំនុចខ្សែស្រប **N $11^{0}$ 09' 03 : 75** និងរយៈទទឹង **E $104^{0}$ 50' 45 : 88** ។

**ទីតាំងសម្លាប់អូរតាមោគ** លេខកូដភូមិសាស្ត្រ: ២១០៧០៦

អូរតាមោក ជាទីតាំងសម្លាប់មនុស្សដ៏ធំមួយកាលពីជំនាន់ខ្មែរក្រហម ។ ទីតាំងនេះស្ថិតនៅខាងលិចវត្តបាណាប្រហែល៥០ម៉ែត្រក្នុងភូមិប៉ាណា ឃុំសឹង្ហ ស្រុកសំរោង ។ ការសម្លាប់មនុស្សនៅអូរតាមោកនេះប្រព្រឹត្តិទៅនៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ ។ ប្រជាជនដែលត្រូវយកមកសម្លាប់នៅទីនេះ ស្ទើរតែទាំងអស់គឺជាប្រភេទដែលពួកខ្មែរក្រហមគិតថាជានាយទុន សក្តិភូមិ និងមូលធននិយម ។ លោកតាទឹម ទង អាយុ៧១ឆ្នាំ រស់នៅភូមិទម្លាប់ ឃុំសឹង្ហ ស្រុកសំរោង ខេត្តតាកែវបាននិយាយថាឃើញមានមនុស្សពេញទីធ្លា វត្តប៉ាណា ពេលដែលគាត់ទៅឃ្វាលគោនៅក្បែរៗនោះ ។ តាមការសន្និដ្ឋានរបស់លោកតាគឺ សុទ្ធតែអ្នក ជម្លៀស អ្នកធំៗ និងទាហានចាប់ពីសក្ត័១ឡើងទៅ ។ មានភាគតិចណាស់ដែលមានទាំងគ្រួសារមកជាមួយ ។ ចំណែកអ្នកតូចតាច ឬប្រជាជនសាមញ្ញមិនត្រូវបានប្រមូលយកមកដាក់នៅវត្តប៉ាណានេះទេ ។ លោកតាបាននិយាយបន្តថាមនុស្សទាំងអស់នេះ មុនដំបូងពួកខ្មែរក្រហមជម្លៀសមកដាក់នៅវត្តទន្លាប់ដែលស្ថិតនៅក្នុង ភូមិទន្លាប់ ឃុំសឹង្ហជាបណ្តោះអាសន្នសិន ។ លុះដល់ពេលក្រោយទើបបញ្ជូនកាន់វត្តប៉ាណាដែលមានចម្ងាយប្រហែលជាងមួយគីឡូម៉ែត្រប៉ុណ្ណោះពីវត្តទន្លាប់ ។ ទៅដល់វត្តប៉ាណា អ្នកជម្លៀសទាំងនេះត្រូវបានប្រើឲ្យទៅកាប់រណ្តៅដើម្បីដាំដូងនិងធ្វើស្រែ ។ រណ្តៅដែលកាប់នោះ មួយៗមានទំហំពីរម៉ែត្របួនជ្រុង ឬ ទទឹង២ម៉ែត្រ និងបណ្តោយ៣ម៉ែត្រ ។ លោកតាបញ្ជាក់ថា រណ្តៅទាំងនោះជារណ្តៅដែលជីកកប់ខ្លួនឯងទៅវិញ ព្រោះរយៈពេលក្រោយៗមកទៀត មនុស្សទាំងអស់នោះដែលស្ថិតក្នុងលំនៅបណ្តោះអាសន្នក្នុងទីវត្តប៉ាណា ត្រូវយកទៅសម្លាប់ដាក់ចូលក្នុងរណ្តៅដែលបានជីកនោះទាំងអស់ ។ លោកតានិយាយបន្តថា ក្រោយពេលកប់មិនបានយូរប៉ុន្មានផង ឃើញពួកកងឈ្លបខ្មែរក្រហមបានមកគាស់យកឆ្អឹងសពក្នុងរណ្តៅនោះមកដុត ដើម្បីលាយធ្វើជីដាក់ដំណាំ ។ ក្នុងការគាស់នេះ គឺពួកកងឈ្លបមិនបានគាស់អស់ទេ នៅសល់ច្រើនណាស់ ។ តាមរបាយការណ៍សរុបរបស់លោកតាថាមានចំនួនប្រហែល៨០រណ្តៅ ។ ហើយមានសាកសព៣៤-៥នាក់ក្នុងមួយរណ្តៅ ។ ដូច្នេះចំនួនសាកសពសរុបគឺប្រហែលជា៣០០-៤០០នាក់ ។ លោកពូ ស្រី សុគន្ធ បច្ចុប្បន្នអាយុ៤៥ឆ្នាំ ជាគ្រូបង្រៀននៅសាលាបឋមសិក្សាប៉ាណា បានឃើញនឹងភ្នែកនូវការចាប់ចងមនុស្សពីវត្តប៉ាណាយកទៅសម្លាប់នៅអូរតាមោក ប៉ុន្តែមិនបានឃើញផ្ទាល់ភ្នែកពេលដែលកំពុងសម្លាប់ឡើយ ។ លោកគ្រូបាននិយាយថាការសម្លាប់នោះប្រព្រឹត្តិទៅនៅពេលយប់ក៏មាន ពេលថ្ងៃក៏មាន ហើយបើមានអ្នកណាលួចរត់ តាមទាន់ត្រឹមណាសម្លាប់ចោលត្រឹមហ្នឹង ។ គាត់បានបន្តថា មិន ដែលមានអ្នកណាម្នាក់រត់រួចឡើយ ព្រោះមានអ្នកយាមត្រឹមត្រូវ ហើយម្យ៉ាងទៀតអូរនេះមានបឹងយ៉ាងធំ មួយនៅជាប់ទៀត ។

ចំណែកនៅក្នុងបរិវេណវត្តប៉ាណាវិញ តាមពុទ្ធដីការរបស់ព្រះសង្ឃមួយអង្គគង់នៅវត្តប៉ាណាបានឲ្យដឹងថាជុំវិញព្រះវិហារមានសុទ្ធតែរណ្តៅទាំងអស់

ហើយឃើញមានខោអាវនៅពាសពេញមាត់រណ្តៅនិងខាងក្រៅ ។ ព្រះអង្គមានពុទ្ធដីការបន្តថា ព្រះវិហារវត្តប៉ាណានេះជាមន្ទីរឃុំឃាំងបណ្តោះអាសន្នរបស់ពួកខ្មែរក្រហម ។ ម៉េ សាម៉េត អាយុ៥២ឆ្នាំ មានតួនាទីជានាយកសាលាបឋមសិក្សាបាណា ឃុំសឹង ស្រុកសំរោង ខេត្តតាកែវ បានឲ្យដឹងថា តាំងពីឆ្នាំ១៩៧៩ពេលដែលគាត់ចូលធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាបាណា គាត់បាន ឃើញសាលារៀនទាំងអស់គ្មានដំបូល គ្មានជញ្ជាំង គ្មានទ្វារ និងគ្មានបង្អួច ។ ទីកន្លែងសាលារៀនទាំងមូលគឺពួក ខ្មែរក្រហមយកធ្វើជាកន្លែងចិញ្ចឹមជ្រូក ។ ចំណែកអាគារខាងលិច និងអាគារខាងកើតធ្វើជារោងជាងធ្វើ ម៉ាស៊ីន ។ លោកនាយកបានរំលឹកពីរឿងអតីតកាលដែលបានកើតមាននៅវត្តប៉ាណា និងនៅកន្លែងសម្លាប់អូរ តាមោកថា នៅឆ្នាំ១៩៧៥ ពួកខ្មែរក្រហមបានយកមនុស្សដែលជម្លៀសពីទីក្រុងភ្នំពេញមោស្តុបទុកនៅទីវត្ត ប៉ាណានេះមួយកន្លែងកាលពីខែមេសាចាប់ពីស័ក្ត១រហូតដល់រដ្ឋមន្ត្រី ។ ហើយនៅទីវត្តទម្លាប់នោះមួយកន្លែង ដែរគឺនៅខែមេសាឆ្នាំ១៩៧៥ដូចគ្នា ។ ក្រោយមកទៀតបន្ទាប់ពីមានការសម្លាប់ជាទ្រង់ទ្រាយធំ នៅខែកក្កដា ឆ្នាំដដែលប្រជាជនជម្លៀសទាំងនោះត្រូវបានអង្គការឲ្យផ្លាសទីលំនៅ ។ លោកនាយកបន្តថា «ពេលនោះហើយ ដែលមានការសម្លាប់ជាលក្ខណៈធំកើតឡើងនៅអូរតាមោក» ។ មានរណ្តៅច្រើនណាស់ ចំណែកឯមនុស្សដែល បានស្លាប់ក៏មានចំនួនមិនតិចដែរ ។ ក្រោយការសម្លាប់ ទឹកក៏ឡើងមកលិចរណ្តៅទាំងនោះអស់គ្មានសល់ ។ ដល់ ទឹកស្រកទៅវិញឃើញតែស្នាមក្រហេងក្រហូងពាសពេញទាំងអស់ ។ លោកនាយកបានធ្វើការបញ្ជាក់ម្តងទៀត ថា ការសម្លាប់មនុស្សនៅអូរតាមោកនោះគឺកើតមានតែក្នុងអំឡុងឆ្នាំ១៩៧៥ប៉ុណ្ណោះ ។ ចំណែកឆ្នាំក្រោយៗ ទៀតគឺមានសម្លាប់នៅកន្លែងផ្សេងដូចជានៅទួលអង្គជាដើម ។ ទួលអង្គនេះ គឺមានសម្លាប់តែអ្នកជាប់ខ្សែចិន សម្បុរសៗ.....។ ចំពោះការប៉ាន់ស្មានចំនួនសាកសពដែលបានស្លាប់នៅបរិវេណវត្តប៉ាណា និងអូរតាមោក លោកនាយកបានប៉ាន់ថាមានចំនួនរាប់ម៉ឺននាក់ ដោយគិតទាំងការសម្លាប់នៅក្នុងបឹង អូរ និងក្នុងបរិវេណវត្ត ។ ហើយមនុស្សដែលបានសម្លាប់នៅក្នុងបរិវេណវត្ត គឺសម្លាប់មុនការសម្លាប់ធំនៅអូរតាមោកប្រហែលមួយខែ ប៉ុណ្ណោះ ។ទីតាំងសម្លាប់អូរតាមោកត្រូវបានកំណត់ទុកដោយម៉ាស៊ីនកត់ត្រាភូមិសាស្ត្រតាមផ្កាយរណប នូវចំនុច ខ្សែស្រប **N 11⁰ 05' 00 : 50** និងយេៈទទឹង **E 104⁰ 47' 46 : 31** ។

## ទីតាំងសម្លាប់ទួលអង្គ

លេខកូដភូមិសាស្ត្រៈ ២១០៧០៧

ទួលអង្គ បច្ចុប្បន្នជាទួលមួយដែលលោកអាចារ្យ និងគណៈកម្មការវត្តបាននិងកំពង់កសាងឡើងនូវព្រះ វិហារមួយយ៉ាងថ្មីសន្ធាងនៅលើទួលនេះ ។ ព្រះវិហារដែលទើបកសាងនេះត្រូវបានប្រសិទ្ធិនាមថាវត្តទួលអង្គ ។ តាមសម្តីប្រជាជននៅក្នុងភូមិក្រាំងស្តៅបានឲ្យដឹងថា កាលដើមឡើយ ទួលនេះមានដើមឈើដុះពាសពេញស្ទើរ ចូលមិនរួច ។ លុះដល់សម័យខ្មែរក្រហមកាន់អំណាច ពួកគេក៏យកទួលនេះសម្រាប់សម្លាប់មនុស្សតែម្តង ។

ទួលនេះស្ថិតនៅក្នុងភូមិក្រាំងស្ដោ ឃុំសីង្ហ ស្រុកសំរោង ខេត្តតាកែវ ។ បច្ចុប្បន្នទួលនេះត្រូវបានកែឆ្នៃឲ្យទៅជាទីគោរពបូជាមួយរបស់ប្រជាជនក្នុងភូមិស្ដោ ។ ហើយក៏បានបន្សល់ទុកនូវដីទួលមួយកន្លែងនៅលើទួលនេះ គឺជាកន្លែងតំកល់អដ្ឋិធាតុដែលគាស់បានកាលពីអំឡុងទសវត្សន៍១៩៨០ ។ លោកអ៊ុំសារាយ ហ៊ិន អាយុ៥៤ឆ្នាំ បច្ចុប្បន្នរស់នៅភូមិក្រាំងស្ដោ ឃុំសីង្ហ និងជាគណៈកម្មការវត្តអង្គបាននិយាយថា បានឃើញពួកកងឈ្លបយកមនុស្សទាំងឡាន១មកសម្លាប់នៅលើទួលនេះ ចំពេលដែលលោកអ៊ុំកំពុងធ្វើរោងមួយសម្រាប់ដាក់អ្នកជម្លៀសពីភ្នំពេញដែលមានចម្ងាយប្រហែល៦០០ម៉ែត្រពីកន្លែងសម្លាប់ទៅទិសខាងលិច ។ ប្រជាជនដែលយកមកទីនេះ ច្រើនតែយកមកនៅពេលយប់ គឺម៉ោងប្រហែល៦-៧ល្ងាច ជួនកាលជិតភ្លឺក៏មានដែរ ។ ជួនកាលលោកអ៊ុំឃើញមានក្មេងៗ រត់ពេញតែទីទួលនោះ ប៉ុន្តែមិនដែលមានក្មេងណាម្នាក់រត់រួចខ្លួនឡើយ ។ ព្រំដែនដែលត្រូវកំណត់គឺមួយគីឡូម៉ែត្របួនជ្រុង ។ ជនរងគ្រោះដោយការសម្លាប់នៅទួលអង្គនេះ ភាគច្រើនបំផុតជាប្រជាជនដែលជាប់ខ្សែចិនទាំងមកពីទីក្រុងភ្នំពេញនិងអ្នកដែលនៅក្នុងខេត្តតាកែវ ។ លោកអ៊ុំបានវាយតម្លៃថាអ្នកនៅខេត្តតាកែវនេះ គឺមានមកប្រហែលជា៦ ឬ៧ភូមិឯណោះ ។ ចំណែករណ្ដៅសាកសពនៅទីទួលអង្គនេះ លោកតាបានប៉ាន់ស្មានថាមានរណ្ដៅធំៗចំនួន៦ និងរណ្ដៅតូចៗជាច្រើនទៀត ។ ឯចំនួនសាកសពវិញគឺមានចំនួនប្រហែលពី៣០០០-៥០០០នាក់ ។ នៅមានរណ្ដៅមួយផ្សេងទៀត គឺសម្រាប់តែកប់ខោអាវ ព្រោះមុនពេលសម្លាប់ ពួកខ្មែរក្រហមបានដោះខោអាវចេញពីអ្នកទោសអស់គ្មានសល់ទេ ។ វិធីសម្លាប់គឺវ៉ៃនឹងក្តាររនេះ និងពូថៅ ។ ក្រោយការគាស់រណ្ដៅបន្ទាប់ពីថ្ងៃរំដោះ សង្កេតឃើញនៅមានចំណងជាប់នឹងដៃ និងជើងសាកសព ។ អ្នកសម្លាប់ភាគច្រើនមានអាយុចាប់ពី២០ឡើងដល់៣០ ហើយជាកងឈ្លប ។

មានកន្លែងតំកល់អដ្ឋិធាតុមួយកន្លែងនៅលើវត្តទួលអង្គនេះ បន្ទាប់ពីមានការគាស់ស្ទើរតែគ្រប់រណ្ដៅរួចមកកាលពីរំដោះហើយភ្លាមៗ ។ ប៉ុន្តែក្រោយមក ដោយមានភាពរប៉ាតរប៉ាយមិនគង់វង្ស អដ្ឋិធាតុទាំងនេះត្រូវបានបំផ្លាញស្ទើរទាំងស្រុង ។ ដោយហេតុនេះហើយ ទើបនាពេលថ្មីនេះលោកតា សេក ទួន អាយុ៦៦ឆ្នាំ រស់នៅភូមិក្រាំងស្ដោ ឃុំសីង្ហ បានប្រមូលអដ្ឋិធាតុដែលនៅអាវាត់អារាយនេះទុកម្តុំដោយបានកប់ទៅវិញ ហើយពូនដីធ្វើជាផ្នូរសរុបមួយនៅចំកណ្ដាលដីទួលដែលមានទំហំប្រមាណ១០ម៉ែត្របួនជ្រុង ។ ផ្នូរកប់អដ្ឋិធាតុ នេះ សព្វថ្ងៃមានដាំបង្គោលបួនពទ្ធ័ជុំវិញ ហើយមានធ្វើជារបងផង ។ តាំងពីទសវត្សន៍១៩៨០រហូតមកដល់ ១៩៩០ ទីតាំងកន្លែងនេះត្រូវបានយកធ្វើជាកន្លែងប្រារព្ធពិធីបុណ្យរំលឹកថ្ងៃ២០ឧសភា ដើម្បីរំលឹកថ្ងៃចងកំហឹងចំពោះរបបប៉ុលពត ។ ទោះជាមានការសាងសង់ព្រះវិហារថ្មី និងប្រែក្លាយពីទីតាំងពិឃាតមនុស្សឲ្យទៅជាទីវត្តដែលជាទីគោរពនៃប្រជាជនទាំងពួងក៏ដោយ កន្លែងតម្កល់អដ្ឋិធាតុមិនត្រូវបានរុះរើឡើយ ។ ប៉ុន្តែមិនដឹងជាថ្ងៃក្រោយទៀត អាចរុះរើឬអត់គឺស្រេចតែទៅលើគណៈកម្មការវត្តទួលអង្គប៉ុណ្ណោះជាអ្នកសម្រេច ។ ទីតាំង

*នេះត្រូវបានកំណត់ទុកដោយម៉ាស៊ីនកត់ត្រាភូមិសាស្រ្តតាមផ្កាយរណប  នូវចំនុចខ្សែស្រប* **N 11$^{\underline{0}}$ 09' 03 : 75** *និងរយៈទទឹង* **E 104$^{\underline{0}}$ 50' 45 : 88** ។